# ជំពូក ១១

# សន្និដ្ឋាន និង អនុសាសន៍

## Conclusions and Recommendations

Draft

# ជំពូកទី ១១

# សន្និដ្ឋាន និង អនុសាសន៍

## ១១.១ សន្និដ្ឋាន និងអនុសាសន៍ លើគំរោងវារីអគ្គិសនីស្ទឹងអាតៃ(ផ្នែកហេដ្ឋារចនាសម្ព័ន្ធគំរោង)

### ១១.១.១ សន្និដ្ឋាន ផ្នែកហេដ្ឋារចនាសម្ព័ន្ធទំនប់វារីអគ្គិសនី

ការវាយតំលៃបរិស្ថាន និងសង្គមលើគំរោងវារីអគ្គិសនីអាតៃ ខេត្តពោធិ៍សាត់ របស់ក្រុមហ៊ុន C.H.D (Cambodia) Hydropower Development Co., Ltd. ដែលក្រុមហ៊ុនបានឱ្យ SAWAC Consultants for Development ធ្វើការសិក្សាស្រាវជ្រាវដើម្បីរៀបចំរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាននិងសង្គមនេះអាចធ្វើសេចក្ដីសន្និដ្ឋានដូចតទៅ :

- ការវិនិយោគគំរោងនេះសរុបចំនួន ២៤៦.៨៨៥.៦០០ (ពីររយសែសិបប្រាំមួយលាន ប្រាំបីរយប៉ែតសិបប្រាំពាន់ ប្រាំមួយរយ) ដុល្លាអាមេរិក គឺ១MW ស្មើនឹង ២.០៥៧.៣៨០ (ពីរលាន ហាសិបប្រាំពីរពាន់បីរយប៉ែតសិប) ដុល្លាអាមេរិក និងតំលៃអគ្គិសនីក្នុង ១KWh គឺ ០,០៧១៤ ដុល្លារអាមេរិក។ ផ្អែកតាមបានចុះកិច្ចសន្យា អនុវត្តគំរោង រវាងក្រុមហ៊ុន នេះ និងរាជរដ្ឋាភិបាលកម្ពុជា នាថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០៧ (មានចែងក្នុងឧបសម្ព័ន្ធ១) ។
- គំរោងសាងសង់របស់គំរោងនេះធ្វើឱ្យមានប៉ះពាល់ផ្ទៃដីព្រៃសរុប ៤.១៨៧,៨១ ហ.ត ក្នុងនោះ ការប៉ះពាល់ដោយសារការសាងសង់អាងទាំងពីរ (តំបន់១) ៣.៨៦៩,១៧ ហ.ត, ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធវារីអគ្គិសនី (តំបន់២) ២៧៣,៣៤ ហ.ត និងការសាងសង់ខ្សែបញ្ជូនចរន្ត១១៥គ.វ(តំបន់៣) ចំនួន៤៥,៣០ហ.ត ។
- គំរោងនេះធ្វើឱ្យបាត់បង់ទាំងស្រុងនូវព្រៃស្រោង មានផ្ទៃដី៣.៨៨៤,១២ហ.ត, ព្រៃពាក់កណ្ដាលស្រោងមានផ្ទៃដី ១១៩,៨ហ.ត , ព្រៃល្បាយស្រល់មានផ្ទៃដី ៥ ហ.ត , ព្រៃល្បាយឫស្សី មានផ្ទៃដី ៧០,៤៤ ហ.ត , និងព្រៃគុម្ពោតមានផ្ទៃដី ១០៨,៤៥ ហ.ត ។ យោងតាមការគណនារបស់ក្រុមការងារ SAWAC រកដង់ស៊ីតេនៃមាឌឈើមធ្យម ក្នុងតំបន់គំរោងមាន៧៩,៨ម$^{៣}$/ហ.ត គឺ ១២% ធំជាង ទិន្នន័យរបស់ CHDមានត្រឹមតែ ៦៩,៩៦ម$^{៣}$/ហ.តតែប៉ុណ្ណោះ។ ចំនួនដែលលើសនេះគឺដោយសារការសិក្សាព្រៃឈើរបស់ក្រុមការងារ SAWACមានទំហំធំជាងគឺបានសិក្សាទាំង៣តំបន់ រីឯក្រុមហ៊ុន CHDសិក្សាតែតំបន់អាងទាំងពីរ (តំបន់១)តែប៉ុណ្ណោះ ។
- យោងតាមការសិក្សានៅក្នុងព្រៃស្រោងមានពូជឈើ ១០៣ប្រភេទ (មើលតារាង៣១), ព្រៃពាក់កណ្ដាលស្រោងមានពូជឈើ ៥៥ប្រភេទ (មើលតារាង៣២ (ខ)),ព្រៃល្បាយស្រល់មានពូជឈើ ២៤ប្រភេទ (មើលតារាង៣៣(ខ)), ព្រៃល្បាយឫស្សីមានពូជឈើ៥៦ប្រភេទ (មើលតារាង៣៤(ខ)) និងព្រៃគុម្ពោតមានពូជឈើ២៤ប្រភេទ(មើលតារាង៣៥ (ខ)) ។ ចំពោះប្រភេទឈើទាំងនេះនៅមានជុំវិញតំបន់គំរោងនៅឡើយ ដូចនេះក្រុមហ៊ុនត្រូវសហការជាមួយនាយកដ្ឋានជំរកសត្វព្រៃភ្នំសំកុស និងរដ្ឋបាលព្រៃឈើថែរក្សាព្រៃឈើនៅជុំវិញតំបន់គំរោងឱ្យបានគង់វង្ស ដោយក្រុមហ៊ុនបានគ្រោងថវិកាការពារ និងអភិរក្សព្រៃឈើ និងសត្វព្រៃផងដែរផងដែរ មើលតារាង ៧១ ចំណុច iv ។
- នៅក្នុងតំបន់គំរោង ក្រុមការងារបានរកឃើញពពួកសត្វព្រៃរួមមាន : ថនិកសត្វចំនួន ៥០ប្រភេទ បក្សី ១៣០ ប្រភេទ ឧរង្គសត្វ ៣៦ប្រភេទ មច្ឆជាតិ២១ប្រភេទរស់នៅ។ ដូចនេះមានការប៉ះពាល់ដល់សត្វព្រៃ និងជំរករបស់វា(លំអិតមានចែងក្នុងជំពូក៥កថាខ័ណ្ឌ៥..១.២.២) ក៏ប៉ុន្តែក្រុមហ៊ុននឹងបង្កលក្ខណៈងាយស្រួលសំរាប់ការបំលាស់ទីរបស់ជីវៈចំរុះទាំងនោះទៅកន្លែងព្រៃនៃ តំបន់អភិរក្សក្បែរនោះ ដោយសហការជាមួយស្ថាប័នពាក់ព័ន្ធ និងអង្គការនានាក្នុងតំបន់គំរោង ។

Draft

- ការសាងសង់អាងទី១ ធ្វើឱ្យមានការប៉ះពាល់ដល់ដីប្រើប្រាស់របស់ប្រជាពលរដ្ឋចំនួន ៣៧ គ្រួសារដែលមានដីកសិកម្ម (ស្រែនិងចំការ) ១៨.៩ ហ.ត. ដីបុស្ស ១៦.៧២ហ.ត. ដីកប់សព ២.៤៦ហ.តដីសហគមន៍ព្រៃការពារក្រវាញឃុំអូរសោម ២៧.៦១ ហ.ត ហើយនឹងត្រូវជន្លៀសប្រជាពលរដ្ឋ ចេញពីតំបន់អាងចំនួន៤គ្រួសារទៅចំណុចស្ទឹងតាចាន់ភូមិឆាយលូក(មើលផែនទីលេខ ២) ។ ក្រុមហ៊ុនត្រូវសហការដោះស្រាយជាមួយស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដីក្នុងបញ្ហានេះ ។
- តាមការសិក្សាកំរិតធាទឹកនៅទំនប់ទី២របស់ក្រុមហ៊ុន C.H.D បានឱ្យដឹងថាកំរិតធាទឹកមធ្យមនៅរដូវវស្សាចន្លោះពីខែ កក្កដា-កញ្ញា ឆ្នាំ២០០៧ គឺ៤៤.៨ម$^{៣}$/វិ នៅឆ្នាំ២០០៨ គឺ១៨.៥ម$^{៣}$/វ កំរិតធាទឹកអតិបរមាឆ្នាំ២០០៧ នៅខែកក្កដា គឺ ៣៥២ ម$^{៣}$/វ នៅឆ្នាំ២០០៨ នៅខែមិថុនាគឺ៨២.៥ ម$^{៣}$/វកំរិតធាទឹកអប្បបរមានៅរដូវប្រាំង ពីខែវិច្ឆិកា ដល់ខែមេសា ឆ្នាំ ២០០៧-២០០៨ គឺ ០.៣៨ម$^{៣}$/វ និងកំរិតធាទឹកមធ្យម៤.២៤ម$^{៣}$/វ។ បើប្រៀបធៀបធាទឹកនៅទីតាំងទំនប់ទី២ ឃើញថាមានកំរិតខ្ពស់ជាងធាទឹកនៅទីតាំងទំនប់ទី២មកអគារថាមពលទី២ ដែលមានកំរិតធាទឹកមធ្យម នៅរដូវវស្សាចន្លោះ ពីខែកក្កដា-កញ្ញា ឆ្នាំ២០០៧ គឺ ៥.៤១ ម$^{៣}$/វ នៅឆ្នាំ២០០៨ គឺ២.២៩ ម$^{៣}$/វ កំរិតធាទឹកអតិបរមា ក្នុងឆ្នាំ២០០៧ នៅខែ កក្កដា គឺ៤២.៥៥ម$^{៣}$/វ កំរិតធាទឹក អតិបរមាក្នុងឆ្នាំ ២០០៨ នៅខែមិថុនា គឺ៩.៩៧ ម$^{៣}$/វកំរិតធាទឹកអប្បបរមា នៅរដូវ ប្រាំងពីខែវិច្ឆិកា ដល់ខែមេសា ឆ្នាំ២០០៧ -២០០៨ គឺ ០.០៥ ម$^{៣}$/វ កំរិតធាទឹកមធ្យម ០.៥១ ម$^{៣}$/វ។
- គំរោងក៏នឹងមានការខ្វះខាតទឹករក្សាជីវៈចំរុះរបស់កំណាត់ស្ទឹងអាតៃនៅចន្លោះទំនប់ទី២ និងអគារថាមពលទី២ (តំបន់អន្លង់ល្អាង) ក្នុងពេលប្រតិបត្តិនិងថែទាំគំរោង។ តែដំណោះស្រាយនេះ ក្រុមហ៊ុនបានគណនាធាទឹកដោយយោងតាមទិន្នន័យជលសាស្ត្រជាក់ស្តែង ក្នុងស្ទឹងអាតៃ នៅចន្លោះពីទំនប់ទី២ មកអគារថាមពលទី២នេះ នារដូវប្រាំង ហើយលទ្ធផលបានកំណត់ថា ក្រុមហ៊ុនត្រូវបញ្ចេញទឹកពីទំនប់ទី២ អាងទី២មកអគារថាមពលទី២ឱ្យបានយ៉ាងតិច ១.៥ម$^{៣}$/វិ ឱ្យមិនដាច់ឡើយដើម្បីរក្សាជីវចំរុះ ឱ្យមាននិរន្តរភាព។
- ប្រភពទឹកលើដី(អូរស្ទឹង) និងក្រោមក្នុងតំបន់គំរោងមានការបំពុលពីសកម្មភាពរបស់ជាមធ្យម។ ចំពោះការបំពុលដោយសារធាតុគីមីវិញ មានតិចតួចប៉ុណ្ណោះ ទោះបីជាមានប៉ារ៉ាម៉ែត្រមួយចំនួនលើសពីស្តង់ដាគុណភាពទឹកគួរបស់ក្រសួងឧស្សាហកម្មរ៉ែ និងថាមពល និងស្តង់ដាគុណភាពទឹកក្នុងប្រភពទឹកសាធារណៈសំរាប់រក្សាជីវសាស្ត្រចំរុះរបស់ក្រសួងបរិស្ថានក៏ដោយ ព្រោះវាកើតចេញពីធម្មជាតិក្នុងតំបន់គំរោង និងមានមនុស្សរស់នៅច្រើនក្នុងពេលសាងសង់គំរោងតែប៉ុណោះ សង្ឃឹមថាពេលប្រតិបត្តិថែទាំគំរោង ប្រជាជនចំណូលថ្មីទាំងនោះនឹងត្រឡប់ទៅទីតាំងរស់នៅរបស់គេវិញ ធ្វើឱ្យគុណភាពទឹកស្ទឹងនេះ នឹងមានការល្អឡើងវិញជាមិនខានឡើយ។
- គំរោងនេះពុំមានហេតុប៉ះពាល់ធ្ងន់ធ្ងរទៅលើបរិស្ថាន និងសង្គមទេប្រសិនបើក្រុមហ៊ុនអនុវត្តទៅតាមវិធានការកាត់បន្ថយនូវការប៉ះពាល់អវិជ្ជមានឱ្យដល់កំរិតអប្បបរមានេះ ម្យ៉ាងទៀតក្រុមហ៊ុនមានបទពិសោធន៍ជាច្រើនឆ្នាំនៅប្រទេសចិន និងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ មួយចំនួនទៀតក្នុងការគ្រោង និងរចនាគំរោងនេះ។ ជាឧទាហរណ៍សង្ខេបពីវិធានការការពារ និងកាត់បន្ថយសំរាប់សំណល់ដែលមានសារធាតុប្រេង និងសារធាតុគីមី ឬសំណល់ រឹងផ្សេងៗទៀតក្រុមហ៊ុនត្រូវទុកដាក់គ្រប់គ្រងឱ្យបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស។ បន្ថែមពីលើនេះក្រុមហ៊ុនបំពាក់ឧបករណ៍សំអាតទឹកកខ្វក់ ដែលមានសមត្ថភាពគ្រប់គាន់យោងតាមការបញ្ចេញចោលរបស់គំរោងនេះ។ មិនតែប៉ុណ្ណោះក្រុមហ៊ុនត្រូវសហការជាមួយ ក្រសួង បរិស្ថាននិងស្ថាប័នពាក់ព័ន្ធក្នុងការត្រួតពិនិត្យ និងផ្តល់យោបល់លើសកម្មភាពនៃការគ្រប់គ្រងសំណល់រឹង-រាវជាប្រចាំ។ ប៉ុន្តែគំរោងវារីអគ្គិសនីស្ទឹងអាតៃនេះអាចនឹងមានហានិភ័យកំរិតខ្ពស់ដូចជាការបាក់ភ្នំ ការបាក់ ទំនប់ ជាដើមក្នុងពេលសាងសង់ និងពេលដំណើរការដូចមាន រ៉ាយ៉ាប់លំអិតក្នុងជំពូក ៧នៃរបាយការណ៍ នេះ ។

Draft

ទន្ទឹមនឹងផលប៉ះពាល់អវិជ្ជមានដល់ធនធានធម្មជាតិ និងបរិស្ថានសង្គមមួយចំនួនគំរោងក៏នឹងផ្តល់ផលប្រយោជន៍យ៉ាងសន្ធឹកសន្ធាប់ដល់ប្រជាពលរដ្ឋមូលដ្ឋាន និងសង្គមជាតិទាំងមូលផងដែរដូចជា -:

តាមរយៈគំរោងនេះបានផ្តល់ការងារដល់ប្រជាពលរដ្ឋកម្ពុជាផងដែរ ដូចជាក្នុងដំណាក់កាលសាងសង់គំរោងត្រូវជ្រើសរើសបុគ្គលិក-កម្មករគំរោងរហូតដល់ ៩០០នាក់ ក្នុងនោះប្រជាពលរដ្ឋក្នុងមូលដ្ឋានចំនួន៥០០នាក់ និងបុគ្គលិក-កម្មករចិន ចំនួន ៤០០នាក់ រីឯក្នុងដំណាក់កាលប្រតិបត្តិនិងថែទាំគំរោងនឹងត្រូវជ្រើសរើសបុគ្គលិកកម្មករចំនួន៣០នាក់ក្នុងនោះ ប្រជាពលរដ្ឋមូលដ្ឋានសរុប ១៩ នាក់ និងបុគ្គលិក-កម្មករចិន ១១នាក់ ។

គំរោងនេះ នឹងមានការបណ្តុះបណ្តាលមន្ត្រីជំនាញកម្ពុជាសំរាប់ដំណើរការបន្ត ក្រោយពីក្រុមហ៊ុនបញ្ចប់កិច្ចសន្យាជាមួយរាជរដ្ឋាភិបាល ។

ប្រទេសកម្ពុជានឹងមានទំនប់វារីអគ្គិសនីធំៗដែលមានសមត្ថភាពផលិត ១២០MW ហើយវាអាចផលិតថាមពលអគ្គិសនីបាន ៥០៦.៩៤ ជីហ្គាវ៉ាត់ម៉ោង (GWh)ក្នុងមួយឆ្នាំ គឺប្រមាណជា ៦៧%នៃថាមពលអគ្គិសនីដែលប្រទេសកម្ពុជាផលិតបានសរុបនៅក្នុងឆ្នាំ២០០៥ ហើយគំរោងវារីអគ្គិសនីស្ទឹងអាតៃនេះ នឹងផ្តល់ថាមពលអគ្គិសនីយ៉ាងចំបងអាចឆ្លើយតបដ៏មានប្រសិទ្ធិភាពចំពោះដំណោះស្រាយប្រភពអគ្គិសនីសំរាប់ប្រទេសកម្ពុជាក្នុងរយៈពេលមធ្យម។ នៅពេលគំរោងនេះដំណើរការ ប្រទេសកម្ពុជានឹងមានថាមពលអគ្គិសនីជាងទ្វេរដងនៃកំលាំងថាមពលអគ្គិសនីផលិតសរុបក្នុងឆ្នាំ ២០០៥។ ជាងនេះទៀតគំរោងវារីអគ្គិសនីស្ទឹងអាតៃ នឹងចូលរួមជាមួយគំរោងវារីអគ្គិសនីផ្សេងទៀត ដើម្បីផ្តល់ស្ថេរភាពក្នុងការផ្គត់ផ្គង់អគ្គិសនីដល់ការប្រើប្រាស់នានា ដូចជាតំបន់រោងចក្រឧស្សាហកម្ម តំបន់កសិកម្ម តំបន់ពាណិជ្ជកម្ម តំបន់លំនៅដ្ឋាន ទីសាធារណៈនិងការអភិវឌ្ឍន៍សេដ្ឋកិច្ចប្រទេសជាតិកម្ពុជាក្នុងការរំដោះភាពក្រីក្ររបស់ប្រជាពលរដ្ឋក្នុងតំបន់គំរោង និងទូទាំងប្រទេសព្រមទាំង ធ្វើឱ្យសង្គមជាតិ រីកចំរើនលើគ្រប់វិស័យ។

ដោយសារឥទ្ធិពលនៃការអភិវឌ្ឍន៍គំរោង និងហេដ្ឋារចនាសម្ព័ន្ធរបស់វាអាចបង្កើនចំណូលដល់ប្រជាពលរដ្ឋក្នុងសហគមន៍មូលដ្ឋានតាមរយៈទេសចរណ៍ជាតិ និងអន្តរជាតិមកតំបន់អូរសោម និងការទស្សនាទំនប់វារីអគ្គិសនីស្ទឹងអាតៃនិងធ្វើអេកូទេសចរណ៍ទៀតផង ។

គំរោងវារីអគ្គិសនីស្ទឹងអាតៃអាចជួយបន្ថយជំនន់ធំៗក្នុងតំបន់ស្ទឹងកោះប៉ោបានមួយផ្នែក ដូចជាបើជំនន់ដើមរដូវវស្សាអាចទប់បានមួយផ្នែកធំ តែបើជំនន់ចុងរដូវវស្សានោះអាចទប់បានមួយផ្នែកតូចប៉ុណ្ណោះ។ ម្យ៉ាងទៀតគំរោងនឹងមានការប្រលែងបញ្ចេញទឹកពីអាងទី២ចំនួន១.៥ម$^{3}$/វិនាទី ទៀងទាត់ឥតដាច់ឡើយដើម្បីធ្វើឱ្យកំណាត់ស្ទឹងអាតៃចាប់ពីទំនប់ទី២នេះដល់អគារថាមពលទី២មានលំនឹងបរិស្ថានល្អប្រសើរឡើងវិញ។

បរិមាណដ៏ធំធេងនៃអាងទឹកនោះអាចបង្កលក្ខខ័ណ្ឌសមស្របសំរាប់ការអភិរក្ស និងការកើនឡើងនៃប្រភេទត្រីមួយចំនួនធំក្នុងតំបន់ស្ទឹងអាតៃផ្នែកខាងលើក្នុងអាងទី១ ព្រោះជំរៅទឹកជាមធ្យមពី ៨ ទៅ ២០ មប៉ុណ្ណោះ ។

គំរោងនេះបានសាងសង់ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់នៅក្នុងតំបន់នេះ ដូចជា កែលំអផ្លូវចេញចូលប្រមោយ-អូរសោម៣០គ.ម. ស្តាពង្រីកផ្លូវពីកោះកុងមកអនុស្ថានីយ៍អូរសោម២៣គ.ម. ធ្វើផ្លូវថ្មីពីចំណុចដំណាក់ក្បួន-អនុស្ថានីយ៍អូរសោម បាន៥៧គ.ម និងសាងសង់ស្ពានបាលេដែកឆ្លងស្ទឹងអាតៃបានប្រវែង៥២ ម និងស្ពានដំណាក់ក្បួនប្រវែង ១៨៧មឆ្លងកាត់ស្ទឹងតូច។ ក្រៅពីហេដ្ឋារចនាសម្ព័ន្ធបំរើឱ្យសាធារណៈជន គំរោងមានសាងសង់អគារស្នាក់នៅឱ្យបុគ្គលិកកម្មករ ការិយាល័យ សួនច្បារ និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗទៀតសំរាប់ការប្រើប្រាស់របស់បុគ្គលិកគំរោង និងធ្វើឱ្យមានសោភណ្ឌ័ភាពដល់តំបន់គំរោងទាំងមូលទៀតផង។

Draft

ដោយសារឥទ្ធិពលនៃការអភិវឌ្ឍន៍គំរោង និងហេដ្ឋារចនាសម្ព័ន្ធរបស់វា អាចនឹងធ្វើឱ្យដីក្នុងតំបន់កើនតំលៃខ្ពស់ជាង បច្ចុប្បន្ន នេះ (២០០៨) ជាពិសេសការប្រើប្រាស់ដីសំរាប់វិស័យឧស្សាហកម្ម កសិកម្មទំនើប និងទេសចរណ៍។ ដោយសារហេដ្ឋារចនាសម្ព័ន្ធរបស់ គំរោងអាចទាក់ទាញអ្នកទេសចរណ៍ជាតិ និងអន្តរជាតិមកទស្សនានៅក្នុងតំបន់គំរោង តំបន់អូរសោមទៅតំបន់ ឆាយប្រុយ តំបន់ស្ទឹងឫស្សីជ្រុំ និងតំបន់ក្បែរខាងនៅថ្ងៃអនាគតយ៉ាងសន្ធឹកសន្ធាប់ទៀតផង ហើយនឹងធ្វើឱ្យខេត្តពោធិ៍សាត់ទាំងមូលក្លាយជាតំបន់ទេសចរណ៍ និងមានធនធានប្រភពថាមពលអគ្គិសនីយ៉ាងសំខាន់មួយសំរាប់ប្រទេសកម្ពុជាយើងផងដែរ ។

គំរោងមានការបង់ផ្ទាល់ចូលចំណូលថវិកាជាតិដោយសារ ក្រុមហ៊ុននឹងត្រូវបង់ពន្ធអាករលើការនាំចូលប្រេងឥន្ធនៈ សំរាប់ប្រើប្រាស់ក្នុងការសាងសង់ ពន្ធកាត់ទុកពន្ធលើប្រាក់ចំណេញ និងពន្ធអាករផ្សេងៗទៀតក្នុងរយៈពេលប្រតិបត្តិការ និងថែទាំគំរោងទៅតាមកិច្ចសន្យារវាងក្រុមហ៊ុនជាមួយរាជរដ្ឋាភិបាលកម្ពុជា ។

**១១.១.២ អនុសាសន៍ ផ្នែកហេដ្ឋារចនាសម្ព័ន្ធទំនប់គំរោងវារីអគ្គិសនី**

ដើម្បីទទួលបានភាពរលូនក្នុងការអនុវត្តន៍គំរោងវារីអគ្គិសនីស្ទឹងអារ៉ែង និងពង្រឹងភាពទទួលខុសត្រូវចំពោះកិច្ចអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយនិរន្តរភាពលើធនធានធម្មជាតិ និងសុវត្ថិភាពសង្គមនោះតាមរយៈការសិក្សាវាយតំលៃផលប៉ះពាល់បរិស្ថាន និងសង្គមសំរាប់គំរោងវារីអគ្គិសនីនេះ SAWAC សូមផ្តល់អនុសាសន៍សំខាន់ៗមួយចំនួនដូចតទៅ -:

- ក្រុមហ៊ុនត្រូវធានាថាគុណភាពសំណង់ទំនប់ទាំងពីរ នៃវារីអគ្គិសនីនេះអាយុកាលរបស់បេតុងគឺ ១០០ ឆ្នាំ។
- មុននឹងដំណើរការគំរោង ត្រូវធ្វើការសាកល្បង ឬធ្វើតេស្ត រាល់សំរេងទំនប់ ទូនេល ទួប៊ីន ជាដើម។ល។ ដោយជឿជាក់ថាគ្រប់រាល់សំណង់ទាំងនោះ គ្មានការលេចជ្រាប ឬជិតល្អ ដំណើរការបានល្អ ដល់អាយុកាល ដែលបានកំណត់ក្នុងការគ្រោងរចនាគំរោង ឬតាមសៀវភៅបន្ទុក ឬតាមកាតាឡុក។ បើមានការខុសពីប្រក្រតីត្រូវធ្វើការជួសជុលជាបន្ទាន់ ឬសង់ឡើងវិញ ឬប្តូរជាថ្មីវិញ។
- ក្រុមហ៊ុនគួរធ្វើកិច្ចសហការជាមួយរដ្ឋាភិបាលកម្ពុជា ដែលតំណាងដោយក្រសួងពាក់ព័ន្ធ ត្រូវលើកផ្លាកឬប៉ាន់ណូហាមឃាត់ការកាប់ឈើ ការបបាញ់សត្វព្រៃ ការលុកលុយរកក្រញូង ការចាប់ដីធ្វើកម្មសិទ្ធ ខុសច្បាប់ ក្នុងតំបន់ព្រៃការពារភ្នំក្រវាញកណ្តាល ព្រៃការពារដងទង់ និងតំបន់ការពារដែនជំរកសត្វព្រៃភ្នំសំកុស ឱ្យបានច្រើនកន្លែង។







- ក្រុមហ៊ុនគប្បីស្តារ និងជួសជុលតំបន់យកថ្មនៅទឹកធ្លាក់ឆាយប្រុយ នៅពេលសាងសង់គំរោងរួច ដោយសហការជាមួយអាជ្ញាធរ និងស្ថាប័នដើម្បីបង្កើតជាតំបន់ទេសចរណ៍ធម្មជាតិ។
- ក្រុមហ៊ុនគប្បីធ្វើសហប្រតិបត្តិការយ៉ាងពេញទំហឹង(ទាំងថវិកា និងបច្ចេកទេស)ជាមួយរដ្ឋបាលព្រៃឈើ អង្គការCI , អង្គការ FFI ,ក្រសួងបរិស្ថាន , និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទដើម្បីធ្វើការអភិរក្សព្រៃឈើ ដើម្បីស្តារព្រៃឈើឡើងវិញក្នុងតំបន់ក្បែរខាង និងតប់ស្កាត់ការទន្ទ្រានកាន់កាប់ដីព្រៃឈើធ្វើជាកម្មសិទ្ធិ

Draft

តាមរយៈការបង្កើតជាសហគមន៍ការពារព្រៃឈើតាមដងផ្លូវចេញចូលតំបន់គំរោងទាំងនោះបានន័យថា គំរោងបានរួមចំណែកស្តារឡើងវិញនូវការបាត់បង់ព្រៃឈើ និងជាជំរកសត្វព្រៃហើយធ្វើឱ្យមានលំនឹងបរិស្ថាននៃការអភិរក្សភ្នំក្រវាញកណ្តាល ព្រៃការពារដងទង់ និងដែនជំរកសត្វព្រៃភ្នំសំកុសនេះទៀតផង ។

- ក្រុមហ៊ុនត្រូវធ្វើការបញ្ចេញទឹកពីទំនប់ទីពីរមកខ្សែទឹកខាងក្រោម តាមទ្វារទឹកលើខ្នងទំនប់បង្ហៀរដើម្បីធ្វើឱ្យទឹកដែលបញ្ចេញមកនេះមានអុកស៊ីសែនគ្រប់គ្រាន់មិនប៉ះពាល់ដល់ជីវសាស្ត្ររស់នៅក្នុងទឹកក្នុងតំបន់អន្លង់ល្ពាងដោយធានានូវបរិមាណធារទឹកយ៉ាងតិចបំផុត ២ម៣/វិ យ៉ាងទៀងទាត់ឥតដាច់ទាំងរដូវប្រាំង និងរដូវវស្សា (ទោះបីក្រុមហ៊ុនខ្វះទឹក បិទទ្វារទឹកដើម្បីបំពេញអាងក៏ដោយ) ដើម្បីធ្វើឱ្យកណាត់ស្ទឹងនេះមានលំនឹងបរិស្ថានកាន់តែប្រសើរ ។
- គំរោងគួរតែសិក្សាតាមដាននូវការលិចជ្រាបទឹកចេញពីអាងឱ្យបានហ្មត់ចត់ នៅក្នុងដំណាក់កាលប្រតិបត្តិ ថែទាំគំរោង ។
- ក្រុមហ៊ុនត្រូវមានការប្រុងប្រយ័ត្ន និងត្រៀមគ្រប់គ្រងហានិភ័យឱ្យបានកំរិតខ្ពស់ដូចជាការសិក្សាភូគព្ភសាស្ត្រ និងបរិស្ថានក្នុងតំបន់គំរោងឱ្យបានហ្មត់ចត់ ការរចនាប្លង់ គុណភាពសំណង់ធានាបានមិនឱ្យមានការ បាក់ទំនប់ បាក់ភ្នំ ។ នៅក្នុងដំណាក់កាលប្រតិបត្តិថែទាំគំរោងត្រូវតាមដានទឹកក្រោមដីជាប្រចាំ ដោយធ្វើការសិក្សាបំរែបំរួលលក្ខណៈរបស់វា ព្រោះវាជាកត្តាមួយទាក់ទងទៅនឹងបាតុភូតរអិលនៃការបាក់ភ្នំ។ ជាងនេះទៅទៀតត្រូវត្រៀមគ្រប់គ្រងរាល់ហេតុការណ៍ដែលអាចកើតឡើងចៃដន្យដោយប្រព័ន្ធផ្សព្វផ្សាយគ្រប់គ្រាន់ និងទាន់ពេលវេលាមានអ្នកជួយសង្គ្រោះ និងសម្ភារសង្គ្រោះ ព្រមទាំងថវិកាសំរាប់ដោះស្រាយជាបន្ទាន់ទៀតផង ។
- រាល់ដំណាក់កាលនៃគំរោងក្រុមហ៊ុនគួរតែអនុវត្តទៅតាមច្បាប់ដែលពាក់ព័ន្ធនៃព្រះរាជាណាចក្រកម្ពុជាដើម្បីឱ្យគំរោងប្រកបទៅដោយជោគជ័យ និងមាននិរន្តរភាពទៅតាមសង្គមកម្ពុជា ។

Draft

## ១១.២ សន្និដ្ឋាន និងអនុសាសន៍លើគំរោងវារីអគ្គិសនីស្ទឹងអាតៃ (ផ្នែកប្រព័ន្ធខ្សែចម្លង)

### ១១.២.១ សន្និដ្ឋាន ផ្នែកប្រព័ន្ធខ្សែចម្លង

ការវាយតំលៃបរិស្ថាន និងសង្គមលើគំរោងខ្សែបញ្ជូនតង់ស្យុងខ្ពស់ ១១៥ kV ពីរខ្សែពីអគារថាមពលទី១-អនុស្ថានីយអូរសោម និងពីអគាថាមពលទី២-អនុស្ថានីយអូរសោម របស់ក្រុមហ៊ុន C.H.D ដែលក្រុមហ៊ុនបានឱ្យ SAWAC Consultants for Development ធ្វើការសិក្សាស្រាវជ្រាវដើម្បីរៀបចំរបាយការណ៍ វាយតំលៃហេតុប៉ះពាល់បរិស្ថាននិងសង្គមនេះ អាចធ្វើសេចក្តីសន្និដ្ឋាន ដូចតទៅ :

- ខ្សែទី១គឺពីអគារថាមពលទី១-អនុស្ថានីយអូរសោមមានប្រវែង ៤.១២គ.ម និងមានបង្គោលចំនួន១១។ ខ្សែទី២គឺពីអគារថាមពលទី២-អនុស្ថានីយអូរសោមមានប្រវែង ១៣.៤៥គ.ម និងមានបង្គោលចំនួន ៣៣។
- ទុនវិនិយោគសំរាប់ប្រព័ន្ធខ្សែចម្លង ៣.៤៨២.៧០០ (បីលាន បួនរយប៉ែបសិបពីរពាន់ ប្រាំពីររយ) ដុល្លារអាមេរិក។ ការវិយោគលើប្រព័ន្ធខ្សែចម្លងនេះរួមមាន: ខ្សែចម្លងតង់ស្យុងខ្ពស់ ១១៥ គ.វ៉ ពីអគារថាមពលទី១ ដល់អនុស្ថានីយអូរសោមចំនួន៧៣៩.៥០០,០០ដុល្លារអាមេរិក. ខ្សែចម្លងតង់ស្យុងខ្ពស់១១៥គ.វ៉ ពីអគារថាមពលទី២ ដល់អនុស្ថានីយអូរសោមចំនួន ២.៧៤៣.២០០,០០ ដុល្លារ អាមេរិក។
- តំបន់២ ដែលជាតំបន់តាមគន្លងខ្សែបញ្ជូនចរន្ត១១គ.វ៉ មានសរុប ៥២.៧១ហ.ត (ក្នុងនោះស្ថិតនៅក្រៅតំបន់១ និងតំបន់២ចំនួន ៤៨.៤៤ហ.ត និងក្នុងតំបន់១ និងតំបន់២ចំនួន៤.២៧ហ.ត)។ នៅក្នុងតំបន់៣នោះមានដីប្រជាជនចំនួន ២.៨៦ ហ.ត និង ០.២៨ ហ.ត ជាដីអូរ និងផ្លូវ រួមទាំងមានការប៉ះពាល់ដីព្រៃស្រោង ៤០.០៣ហ.ត និងព្រៃល្បាយ ឬស្សី ៥.២៧ហ.ត។
- ខ្សែបញ្ជូនចរន្តតង់ស្យុងខ្ពស់ ១១៥គ.វ៉ នេះមានការប៉ះពាល់ដីប្រជាពលរដ្ឋចំនួន២គ្រួសារ ដែលដីរបស់ពពួកត្រូវចំ ៦ បង្គោលភ្លើង ត្រូវជា ១៣៥០ម$^2$ (ខ្សែទី១បង្គោល A9,A10,JA4 និង ខ្សែទី២បង្គោល B54, B55, JB9)
- ព្រៃឈើ ដំណាំយុទ្ធសាស្ត្រ កំពស់លើសពី ៣ម នៅពីក្រោមគន្លងខ្សែចម្លងម្ខាង ១៥មនៃអក្សបង្គោលភ្លើង ពោលគឺក្រោមដីចំណីខ្សែចម្លងសរុប ៣០មចាត់ទុកថាព្រៃឈើ ដំណាំយុទ្ធសាស្ត្រទាំងនោះមានការប៉ះពាល់អវិជ្ជមានដែលត្រូវកាប់កាប់សំអាតចោលតាមបទដ្ឋានបច្ចេកទេសព្រៃឈើ។
- ការរស់នៅក្រោមចំណីដីខ្សែចម្លង៣០ម និងចំទីតាំងសំរាប់ការសាងសង់បង្គោលភ្លើងរបស់ប្រជាពលរដ្ឋត្រូវប៉ះពាល់អវិជ្ជមានដែលបានគិតគូរ និងដោះស្រាយសមស្រប និងយុត្តិធម៌។
- គំរោងនេះពុំមានហេតុប៉ះពាល់ធ្ងន់ធ្ងរទៅលើបរិស្ថាន និងសង្គមទេ ប្រសិនបើក្រុមហ៊ុនអនុវត្តទៅតាមវិធានការកាត់បន្ថយនូវការប៉ះពាល់អវិជ្ជមានឱ្យដល់កំរិតអប្បបរមាដែលបានចែងក្នុងរបាយការណ៍នេះ។ ម្យ៉ាងទៀតក្រុមហ៊ុនមានបទពិសោធន៍ជាច្រើនឆ្នាំនៅប្រទេសចិន និងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួនទៀត ក្នុងការគ្រោងរចនា និងសាងសង់គំរោងនេះ។ ជាឧទាហរណ៍សង្ខេបពីវិធានការការពារ និងកាត់បន្ថយសំរាប់សំណល់ដែលមានសារធាតុប្រេង និងសារធាតុគីមី ឬសំណល់រឹងផ្សេងៗទៀត ក្រុមហ៊ុននឹងទុកដាក់គ្រប់គ្រងឱ្យបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស។ ម្យ៉ាងទៀតក្រុមហ៊ុនមិនប្រើប្រាស់សារធាតុគីមីដែលធ្វើឱ្យប៉ះពាល់ដល់បរិស្ថាន និងសង្គមនោះទេ។ មិនតែប៉ុណ្ណោះ ក្រុមហ៊ុននឹងត្រូវសហការជាមួយក្រសួងបរិស្ថាន និងស្ថាប័នពាក់ព័ន្ធក្នុងការត្រួតពិនិត្យ និងផ្តល់យោបល់លើសកម្មភាពនៃការគ្រប់គ្រងសំណល់រឹងរាវជាប្រចាំ។

Draft

- គំរោងខ្សែបញ្ជូនចរន្តតង់ស្យុងខ្ពស់នេះអាចនឹងមានហានិភ័យកំរិតខ្ពស់ដូចជា ការបាក់រលំបង្គោល និងដាច់ខ្សែភ្លើងជាដើម ដោយសារគ្រោះធម្មជាតិ ក្នុងពេលសាងសង់ និងពេលដំណើរការ ដូចមានរៀបរាប់លំអិតក្នុង ជំពូក៨ នៃរបាយការណ៍នេះ ។

ទន្ទឹមនឹងផលប៉ះពាល់អវិជ្ជមានដល់ធនធានធម្មជាតិ និងបរិស្ថានសង្គមមួយចំនួន គំរោងក៏ផ្តល់ផលប្រយោជន៍យ៉ាងសន្ធឹកសន្ធាប់ដល់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាន និងសង្គមជាតិទាំងមូលផងដែរដូចជា-:

- តាមរយៈគំរោងនេះផ្តល់ការងារដល់ប្រជាពលរដ្ឋកម្ពុជាផងដែរ ដូចជាក្នុងដំណាក់កាលសាងសង់បុគ្គលិក-កម្មករគំរោងត្រូវជ្រើសរើសបុគ្គលិក-កម្មករសរុប៥២នាក់ ក្នុងនោះកម្មករជាប្រជាពលរដ្ឋមូលដ្ឋានសរុប៤០នាក់ និងបុគ្គលិក-កម្មករចិន ១២នាក់។ រីឯនៅដំណាក់កាលប្រតិបត្តិការនិងថែទាំគំរោង ក្រុមហ៊ុនមានភារកិច្ចទទួលខុសត្រូវខ្សែបញ្ជូនតង់ស្យុងខ្ពស់១១៥គ.វ៉ ដោយត្រូវការអ្នកគ្រប់គ្រង និងអ្នកទទួលខុសត្រូវតាមផ្នែកជំនាញសរុបចំនួន១២នាក់ ក្នុងនោះបុគ្គលិកកម្ពុជាចំនួន ០២នាក់ និងបុគ្គលិកចិនចំនួន ១០នាក់។

- ដោយឡែកក្រុមហ៊ុន នឹងផ្ទេរទៅឱ្យក្រុមហ៊ុនអគ្គិសនីកម្ពុជាជាអ្នកទទួលខុសត្រូវ និងគ្រប់គ្រងបន្តតាមកិច្ចព្រមព្រៀង ជាមួយរាជរដ្ឋាភិបាលកម្ពុជា ។តាមរយៈការផ្ទេរនេះនឹងធ្វើឱ្យមានការផ្តល់ការងារធ្វើដល់បុគ្គលិក វិស្វករកម្ពុជាថែមទៀត ក្នុងដំណាក់ការប្រតិបត្តិនិងថែទាំគំរោងក្នុងរយៈពេល៣០ឆ្នាំខាងមុខនេះ ។

- គំរោងមានផែនការបណ្តុះបណ្តាលបុគ្គលិកកម្ពុជាផងដែរលើផ្នែកបច្ចេកទេសនិងគ្រប់គ្រងដើម្បីបន្តដំណើរការនៅពេល ដែលក្រុមហ៊ុនបញ្ចប់កិច្ចសន្យាវិនិយោគគំរោងនេះ ជាមួយរាជរដ្ឋាភិបាលកម្ពុជា។

- ការអភិវឌ្ឍន៍ប្រព័ន្ធខ្សែចម្លងតង់ស្យុងខ្ពស់នេះ អាចនឹងធ្វើឱ្យមានការផ្គត់ផ្គង់ចរន្តអគ្គិសនី ទៅកាន់តំបន់នានានៅតាមបណ្តាខេត្តមួយចំនួនដែលមានអនុស្ថានីយតភ្ជាប់ ពីរអនុស្ថានីយ៍អូរសោម រួមមានខេត្តពោធិ៍សាត់ ខេត្តបាត់ដំបង ខេត្តកំពង់ឆ្នាំង និងខេត្តកំពង់ស្ពឺ។ តាមរយៈប្រព័ន្ធខ្សែចម្លងអូរសោម-ពោធិ៍សាត់នេះប្រជាពលរដ្ឋនឹងរស់នៅខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង និង ខេត្តកំពង់ស្ពឺ រាជធានីភ្នំពេញទទួលបានអគ្គិសនីប្រើប្រាស់គ្រប់គ្រាន់ និងមានតំលៃថោកទៀតផង។

- ជាងនេះទៀតគំរោងនេះនឹង ចូលរួមជាមួយគំរោងវារីអគ្គិសនីផ្សេងទៀត ដើម្បីផ្តល់នូវស្ថេរភាពក្នុងការផ្គត់ផ្គង់ភ្លើងអគ្គិសនីដល់ការប្រើប្រាស់នានា ដូចជាតំបន់រោងចក្រឧស្សាហកម្ម តំបន់កសិកម្ម តំបន់ពាណិជ្ជកម្ម តំបន់លំនៅដ្ឋាន ទីសាធារណៈ និងការអភិវឌ្ឍន៍សេដ្ឋកិច្ចប្រទេសជាតិកម្ពុជាដើម្បីចូលរួមកាត់បន្ថយភាពក្រីក្ររបស់ ប្រជាពលរដ្ឋក្នុងតំបន់គំរោង និងទូទាំងប្រទេសព្រមទាំងធ្វើឱ្យសង្គមជាតិរីកចំរើនលើគ្រប់វិស័យ ។

- គំរោងមានការបង់ផ្ទាល់ចូលចំណូលថវិកាជាតិដោយសារ ក្រុមហ៊ុននឹងត្រូវបង់ពន្ធអាករលើការនាំចូលប្រេងឥន្ធនៈសំរាប់ប្រើប្រាស់ក្នុងការសាងសង់ ពន្ធកាត់ទុក ពន្ធលើប្រាក់ចំណេញ និងពន្ធអាករផ្សេងៗទៀតក្នុងរយៈពេលប្រតិបត្តិការ និងថែទាំ គំរោងទៅតាមកិច្ចសន្យារវាងក្រុមហ៊ុនជាមួយរាជរដ្ឋាភិបាលកម្ពុជា ។

## ១១.២.២ អនុសាសន៍ ផ្នែកប្រព័ន្ធខ្សែបញ្ជូនចរន្ត

ដើម្បីទទួលបានភាពរលូនក្នុងការអនុវត្តន៍គំរោង BOT នៃការសាងសង់ប្រពន្ធ័បណ្តាញខ្សែបញ្ជូនចរន្តអគ្គិសនីតង់ស្យុងខ្ពស់ ១១៥គ.វ៉ និងពង្រឹងភាពទទួលខុសត្រូវចំពោះកិច្ចអភិវឌ្ឍន៍ សេដ្ឋកិច្ចប្រកបដោយនិរន្តរភាពលើធនធានធម្មជាតិ និងសុវត្ថិភាពសង្គម នោះតាមរយៈការសិក្សាវាយតំលៃផលប៉ះពាល់បរិស្ថាន និងសង្គមសំរាប់គំរោងនេះ Sawac សូមផ្តល់អនុសាសន៍សំខាន់ៗមួយចំនួនដូចតទៅ -:

- ក្រុមហ៊ុនត្រូវរៀបចំសហការជាមួយអាជ្ញាធរដែនដីដើម្បីដាក់ផ្លាកធំៗអំពី សេចក្តីជូនដំណឹងអំពីចំណីខ្សែ ១១៥ គ.វ៉ និងការសាងសង់សំណង់ផ្សេងៗរួមទាំងការដំណាំផ្សេងៗនៅក្រោមគន្លងទឹង ៣០ម.នៃខ្សែនេះឱ្យបានច្រើន នៅតាមបង្គោលភ្លើង។

Draft

- ក្រុមហ៊ុនត្រូវរៀបចំសហការជាមួយអាជ្ញាធរដែនដីដើម្បីដាក់ផ្លាកធំៗអំពី សេចក្តីជូនដំណឹងអំពីចំណីខ្សែ ១១៥ គ.វ៉ និងការសាងសង់សំណង់ផ្សេងៗរួមទាំងការដំណាំផ្សេងៗនៅក្រោមគន្លងទីង ៣០ម.នៃខ្សែនេះឱ្យបានច្រើន នៅតាមបង្គោលភ្លើង ។




- ក្រុមហ៊ុនគប្បីធ្វើការពិភាក្សាជាមួយស្ថាប័នជំនាញក្នុងការដឹកជញ្ជូនត្រង់ស្វូដែលមានទំងន់ធ្ងន់ ដែលអាចបណ្តាលឱ្យកើតមានគ្រោះថ្នាក់ចរាចរណ៍ ខូចផ្លូវ បាក់ស្ពាន ជាដើម ។ល ។
- ក្រុមហ៊ុនគប្បីសហការជាមួយអាជ្ញាធរ និងមន្ទីរពាក់ព័ន្ធដើម្បីជួសជុលផ្លូវ ឬលូ ឬស្ពាន ដែលខូចខាតដោយការដឹកសម្ភារសំណង់របស់ខ្លួន ។
- ក្រុមហ៊ុនគប្បីធ្វើការចុះត្រួតពិនិត្យបណ្តាញជាប្រចាំអំពីសុវត្ថិភាពតាមគន្លងខ្សែនេះ ដូចជាកំពស់ដើមឈើ មិនឱ្យលើសពី៣ម គ្មានសំណង់ផ្សេងៗក្រោមគន្លងខ្សែដើម្បីជៀសវាងការប៉ះពាល់ដល់សុខភាពសុវត្ថិភាពរបស់ប្រជាពលរដ្ឋរួមទាំងសត្វផងដែរ ។
- ក្រុមហ៊ុនគប្បីសហការជាមួយមន្ទីរពាក់ព័ន្ធដើម្បីពិនិត្យមើលខ្មៅរឹតបង្គោលទៅគ្រឹះបង្គោល ដោយជឿជាក់ថាខ្មៅទាំងនោះបានរឹតតឹងហើយពុំមានការបាត់បង់ឡើយ ។
- ក្រុមហ៊ុនគប្បីធ្វើសហប្រតិបត្តិការយ៉ាងពេញទំហឹង (ទាំងថវិកា និងបច្ចេកទេស) ជាមួយក្រសួងបរិស្ថាន ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បដោះស្រាយនូវវិធានការបន្ធូរបន្ថយហេតុប៉ះពាល់បរិស្ថាន និងសង្គមដែលអាចកើតឡើងជាយថាហេតុដោយសារគ្រោះធម្មជាតិ ផ្សេងៗ ។ល ។
- ក្រុមហ៊ុនត្រូវមានការប្រុងប្រយ័ត្ន និងត្រៀមគ្រប់គ្រងហានិភ័យឱ្យបានកំរិតខ្ពស់ដូចជា ការសិក្សាភូគព្ភសាស្ត្រ និងបរិស្ថានក្នុងតំបន់គំរោងឱ្យបានហ្មត់ចត់ ការរចនាប្លង់ គុណភាពសំណង់ធានាដោយមិនឱ្យមានការបាក់រលំបង្គោល ឬដាច់ខ្សែភ្លើងនៅពេលមានព្យុះភ្លៀងដែលធ្លាប់កើតមានឡើងក្នុងប្រទេសកម្ពុជាកន្លងមក(ក្នុងរយៈពេល១០០ឆ្នាំ) ។ ត្រៀមគ្រប់គ្រងហេតុការណ៍ដែលអាចកើតឡើងចៃដន្យ ដោយមានប្រព័ន្ធផ្សព្វផ្សាយគ្រប់គ្រាន់និងទាន់ពេលវេលា និងមានអ្នកជួយសង្គ្រោះ និងសំភារៈសង្គ្រោះព្រមទាំងថវិកាសំរាប់ដោះស្រាយជាបន្ទាន់ទៀតផងដែរនូវពេលមានគ្រោះថ្នាក់ទាំងនេះកើតឡើង ។
- រាល់ដំណាក់កាលនៃគំរោងក្រុមហ៊ុនគួរតែអនុវត្តទៅតាមច្បាប់ដែលពាក់ព័ន្ធនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីឱ្យគំរោងប្រកបទៅដោយជោគជ័យ និងមាននិរន្តរភាព ។

ជាទីបញ្ចប់នេះ ក្រុមហ៊ុន C.H.D (Cambodia) Hydropower Development Co., Ltd. ដែលជាអ្នកសិក្សាគ្រោងរចនាគំរោងសំរាប់អភិវឌ្ឍន៏វារីអគ្គិសនីស្ទឹងអាតៃខេត្តពោធិ៏សាត់ ដែលមានឱកាសផ្តល់នូវផលប្រយោជន៏ជាច្រើនដល់រាជរដ្ឋាភិបាល និងជាពិសេសដល់ប្រជាពលរដ្ឋ ដើម្បីចូលរួមកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៏របស់ប្រទេសជាតិ។ ដូចនេះក្រុមហ៊ុនមានសំណូមពរដល់ក្រសួងបរិស្ថាន និងក្រសួងពាក់ព័ន្ធមួយចំនួនទៀតព្រមទាំងរាជរដ្ឋាភិបាលកម្ពុជាមេត្តាជួយបង្កលក្ខណៈងាយស្រួល និងចេញលិខិតអនុញ្ញាតិ និងទទួលស្គាល់លើរបាយការណ៏វាយតំលៃហេតុពាល់បរិស្ថាន និងសង្គមពេញលេញនេះជាផ្លូវការដោយអនុគ្រោះ ។

| | |
|---|---|
| រាជធានីភ្នំពេញ, ថ្ងៃទី 02.... ខែ [illegible]..... ឆ្នាំ ២០១១ | រាជធានីភ្នំពេញ, ថ្ងៃទី [illegible]..... ខែ [illegible]...... ឆ្នាំ ២០១១ |
| **នាយកក្រុមហ៊ុន** C.H.D ( Cambodia) Hydropower Development Co., Ltd. | **នាយក** SAWAC Consultants for Development |
| SAWAC CONSULTANTS FOR DEVELOPMENT CO.,LTD. | |
| WANG XIAO HONG | ញឹម សារឿន |